ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៤៨/១៤-ភីសគ្គរី (ខេមបូឌា) មេនូហ្វេកឈ័រីង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ភីសគ្គរី (ខេមបូឌា) មេនូហ្វេកឈឺរីង**

អាសយដ្ឋាន ៖ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦៦៧ ១០៧ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោកស្រី ឡេង សុជាតា ប្រធានរដ្ឋបាល

២- លោកស្រី អ៊ឹង ស៊ាមបួយ អ្នកបកប្រែ

៣- លោក ផាន់ សុផល ផ្នែកផលិតកម្ម

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពកម្មករកម្ពុជា**

- **សហជីពកម្មករកម្ពុជា ភីសគ្គរី (ខេមបូឌា) មេនូហ្វេកឈឺរីង**

អាសយដ្ឋាន ៖ ភូមិសឡា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៦៦ ៦៨២/០១២៩១៥ ៤១៧ ទូរសារ ៖ គ្មាន


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត ៖

១- លោក វង់ បូរិត មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា

២- លោក ហួរ ពៅ មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា

៣- លោកស្រី ចាប សម្បត្តិ ប្រធានសហជីពកម្មករកម្ពុជា ប្រចាំរោងចក្រ ភីសគ្គីរី

៤- លោក ឡុង នាន អនុប្រធានសហជីព កម្មករកម្ពុជា ប្រចាំរោងចក្រ ភីសគ្គីរី

៥- លោក នែម សុភណ្ឌ័ លេខាធិការសហជីពកម្មករកម្ពុជា ប្រចាំរោងចក្រ ភីសគ្គីរី

៦- លោក អែម ភារម្យ ហិរញ្ញិកសហជីពកម្មករកម្ពុជា ប្រចាំរោងចក្រ ភីសគ្គីរី

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ចំនួន ២០០០រៀល ក្នុងមួយថ្ងៃ។ ដោយឡែកភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ជូនទេ។

២- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលចំនួន ៥០% សរុបបីខែមុនដោយគិតជាសមាមាត្រចំពោះស្ត្រីដែលឈប់សម្រាបលំហែមាតុភាព។ ដោយឡែកភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលតាមច្បាប់ស្តីពីការងារចំពោះស្ត្រីដែលឈប់សម្រាបលំហែមាតុភាព។

៣- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ជាសមាមាត្រចំនួនថ្ងៃដែលកម្មករនិយោជិតសុំច្បាប់ឈប់សម្រាកដោយមានធុរៈ។ ដោយឡែកភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនរក្សាប្រាក់រង្វាន់ធ្វើការទៀងទាត់ឱ្យ ក្នុងករណីកម្មករនិយោជិតឈប់មានច្បាប់មួយថ្ងៃ បើលើសពីមួយថ្ងៃក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ទាំងអស់ ។

៤- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជាទាំង៤រូប រួមមានឈ្មោះ ចាប សម្បត្តិ ឡុង នាន នែម សុភណ្ឌ័ អែម ភារម្យ ចូលធ្វើការងារវិញជាធម្មតា។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្តីពីលទ្ធផលនៃការដោះស្រាយវិវាទរួម លេខ ២២៦ កប/អក/វក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ** ៖ - ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល

**បញ្ហានៃនីតិវិធី** ៖

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងតាមទូរស័ព្ទ ពីសហជីពកម្មករកម្ពុជា ស្តីពីកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួន ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ដល់ទីតាំងក្រុមហ៊ុន និងធ្វើការផ្សះផ្សាវិវាទនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៧ ចំណុច និងមិនសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ១១ ចំណុច ។ ចំណុចមិនសះជាចំនួន ០៤ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ២២៦ កប/អក/វក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៤។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សា លើករណីមិនសះជាទាំង ០៤ ចំណុច នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ វេលាម៉ោង ០២ និង ០០ នាទី រសៀល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៤ ចំណុចនេះ បន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួនមួយចំណុច គឺចំណុចវិវាទទី៣។ ភាគីកម្មករនិយោជិតសម្រេចដកចំណុចវិវាទទី១ និងទី៤ ចេញពីសំណុំរឿង។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាទៅលើចំណុចវិវាទមិនសះជា ដែលនៅសល់ចំនួន ០១ ចំណុចប៉ុណ្ណោះ គឺ ចំណុចវិវាទទី២។

ថ្វីត្បិតតែសហព័ន្ធសហជីពកម្មករកម្ពុជា និងភាគីនិយោជក ជាភាគីហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ក៏ប៉ុន្តែ ដោយសារសហជីពកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ភីស គ្លូរី មិនទាន់ទទួលឋានៈជាអង្គការវិជ្ជាជីវៈ ព្រោះសហជីពនេះទើបតែធ្វើការបោះឆ្នោតនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៤ និងបានជូនដំណឹងទៅនិយោជកអំពីសមាសភាពជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជា នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចបកស្រាយថា គូភាគីនៃសំណុំរឿងនេះ គឺជាហត្ថលេខីនៃអនុស្សារណៈស្តីពីការយោគយល់គ្នា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ បានឡើយ។

នៅក្នុងសំណុំរឿងនេះ ភាគីទាំងពីរបានជ្រើសរើសយកប្រភេទសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន**

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- បញ្ជីរាយនាម និងស្នាមមេដៃ របស់កម្មករកម្មការិនី ដែលបានចូលជាសមាជិកសហជីពកម្មករកម្ពុជា ចំនួន ៤១២ នាក់។

២- លិខិតផ្ទេរសិទ្ធិជូនលោកស្រី ឡេង សុជាតា ដោយលោកស្រី ស៊ូសាន ឈុន ជានាយកក្រុមហ៊ុន ភីសគ្លូរី (ខេមបូឌា) មេទូហ្វេកឈ័ររីង ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤។

៣- កំណត់ហេតុផ្សះផ្សាវិវាទការងាររួម របស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤។

៤- លិខិតជូនដំណឹងធ្វើកូដកម្មមុន០៧ថ្ងៃ របស់ថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជា និងកម្មករនិយោជិត។

៥- កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុនភីសគ្លូរី នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ រវាងសហព័ន្ធសហជីពកម្មករកម្ពុជា និងក្រុមហ៊ុន។

៦- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១។

៧- លក្ខន្តិកៈក្រុមហ៊ុន ភិស គ្លូរី (ខេមបូឌា) មេទូហ្វេកឈ័ររីង ឆ្នាំ២០០៥។

៨- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ភិស គ្លូរី (ខេមបូឌា) មេទូហ្វេកឈ័ររីង បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ លេខ ០១១ កកបវ/អក/អធក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៦ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

- លិខិតលេខ ៤០៦៤/១៤ សសកក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់សហព័ន្ធសហជីពកម្មករកម្ពុជា គោរពជូន នាយកក្រុមហ៊ុន PEACE GLORY (CAMBODIA) CO., LTD ជូនដំណឹងស្តីពីសមាសភាព ជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជា។

THE ARBITRATION COUNCIL

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- កំណត់ហេតុស្តីពីការផ្សះផ្សាវិវាទការងាររួមនៅ ភិស គ្លូរី ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០១៤។

២- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ភិស គ្លូរី លេខ ២២៦ កប/អក/វក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៣៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៣៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤។

៣- កិច្ចព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ២០១៤។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ភីស គ្លូរី (ខេមបូឌា) មេនូហ្វេកឈ័ររីង (តទៅនេះហៅថា "ក្រុមហ៊ុន ភីស គ្លូរី") ជាក្រុមហ៊ុនដែលមានសកម្មភាពអាជីវកម្មចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់ ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Inv.១០១១ E/២០០៥ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥។ នៅថ្ងៃសវនាការ ភាគីទាំងពីរបានទទួលស្គាល់ថា ក្រុមហ៊ុននេះមានជួលកម្មករនិយោជិតចំនួនសរុបប្រមាណជា ៥០០ នាក់ ។
- សហជីពកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន ភីស គ្លូរី មិនទាន់ទទួលវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពទេ។ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបានអះអាងថា សហជីពនេះ បានទទួលបានបង្កាន់ដៃស្នើសុំចុះបញ្ជិកាសហជីព ប៉ុន្តែមិនចាំពីកាលបរិច្ឆេទនៃការទទួលបានបង្កាន់ដៃនេះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃផ្តល់ភស្តុតាង ឱ្យភាគីកម្មករនិយោជិតផ្តល់បង្កាន់ដៃនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលយ៉ាងយូរត្រឹមថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ប៉ុន្តែភាគីកម្មករនិយោជិតមិនបានដាក់ភស្តុតាងនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។
- ភាគីកម្មករនិយោជិតដែលមានវត្តមាននៅក្នុងថ្ងៃសវនាការ រួមមាន៖ ១) លោក វង់ បូរិត ជាមន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា, ២) លោក ហ៊ួរ ពៅ ជាមន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា, ៣) កម្មករ ចាប សម្បត្តិ ៤) កម្មករ ឡុង នាន ៥) កម្មករ ឆែម សុភ័ណ្ឌ និង ៦) កម្មករ អែម ភារម្យ ។

**ចំណុចវិវាទទី ០២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ឈ្នួលសរុបចំនួន ៥០% សម្រាប់បីខែមុន ដោយគិតជាសមាមាត្រចំពោះស្ត្រីដែលឈប់សម្រាកលំហែមាតុភាព**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករនិយោជិតមិនមានវិវាទលើសិទ្ធិក្នុងការឈប់សម្រាក និងការកំណត់ប្រាក់ឈ្នួលសម្រាប់លំហែមាតុភាពនោះទេ ប៉ុន្តែភាគីកម្មករនិយោជិតទាមទារថា ឱ្យនិយោជកបើកប្រាក់ឈ្នួល ចំនួន ៥០ ភាគរយ ចំនួន ៩០ ថ្ងៃ សរុបមុនពេលកម្មការិនីឈប់សម្រាកលំហែមាតុភាព។
- ភាគីទាំងពីរបានទទួលស្គាល់ថា នៅក្នុងក្រុមហ៊ុនមានកម្មការិនីប្រមាណជា ១០ នាក់ ក្នុងមួយឆ្នាំ ដែលសម្រាកលំហែមាតុភាព ហើយកន្លងមក និយោជកបានបើកប្រាក់សម្រាកលំហែមាតុភាពស្មើនឹង ៥០ ភាគរយ នៃប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ គឺ ៖
  - បើកមួយខែម្តងៗ ជូនកម្មការិនី ក្នុងអំឡុងពេលសម្រាកលំហែមាតុភាព
  - ឬបើកបីខែម្តង ក្រោយពេលដែលកម្មការិនី ត្រលប់មកពីសម្រាកលំហែមាតុភាពចូលធ្វើការវិញ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ជាសិទ្ធិដែលមានចែងក្នុងច្បាប់ ដែលកម្មការិនីសម្រាកលំហែមាតុភាព ត្រូវទទួលបានប្រាក់សម្រាកលំហែមាតុភាព មុនពេលដែលពួកគាត់ឈប់ទៅសម្រាកលំហែមាតុភាព។
  - ដោយយោងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៣/១០ ចេញនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកបើកប្រាក់លំហែមាតុភាព ចំនួន ៥០ ភាគរយ ជូនកម្មការិនីដែលសម្រាកលំហែមាតុភាព រយៈពេល ៩០ថ្ងៃសរុប មុនពេល ដែលពួកគាត់ឈប់ទៅសម្រាកលំហែមាតុភាព។
  - ទីលំនៅរបស់កម្មការិនីដែលសម្រាកលំហែមាតុភាព ស្ថិតនៅឆ្ងាយពីក្រុមហ៊ុន ឬនៅតាមបណ្តាខេត្តនានា ដែលពួកគាត់ត្រូវចំណាយពេលវេលា និងថវិកាសម្រាប់ធ្វើដំណើរ ដើម្បីមកបើកប្រាក់លំហែមាតុភាពជារៀងរាល់ខែ។
  - កម្មការិនីត្រូវយកប្រាក់ឈ្នួលសម្រាប់ចំណាយលើថ្លៃសម្រាលកូន និងថ្លៃទឹកដោះគោ ព្រមទាំងសម្ភារៈសម្រាប់ទារក។
- ភាគីនិយោជកបានឆ្លើយតបថា និយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ព្រោះថា និយោជកធ្លាប់ជួបប្រទះ ករណីដែលកម្មការិនីសម្រាកលំហែមាតុភាពដោយបើកប្រាក់លំហែមាតុភាពរយៈពេល ៣ខែមុនពេលឈប់សម្រាកលំហែមាតុភាព ហើយបន្ទាប់មកកម្មការិនីទាំងនោះ មិនត្រឡប់មកបំពេញការងារឱ្យក្រុមហ៊ុនទេ។

## ហេតុផលនៃសេចក្តីសម្រេច ÷

**ចំណុចវិវាទទី ០២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់លំហែមាតុភាពចំនួន ៥០ ភាគរយ សម្រាប់កម្មការិនីឈប់សម្រាកលំហែមាតុភាពចំនួន ៩០ ថ្ងៃ មុនពេលកម្មការិនីឈប់ទៅសម្រាកលំហែមាតុភាព**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះធ្វើការពិចារណាដូចខាងក្រោម ៖

១) តើអ្នកណាជាដើមបណ្តឹងក្នុងសំណុំរឿងនេះ?

តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ២២៦ កប/អក/វក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ សហជីពកម្មករកម្ពុជា គឺជាអ្នកដាក់ពាក្យបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ភីស គ្លូរី មិនទាន់ទទួលវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពទេ។ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបានអះអាងថា សហជីពនេះ បានទទួលបានបង្កាន់ដៃស្នើសុំចុះបញ្ជិកាសហជីព។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃផ្តល់ភស្តុតាង ឱ្យភាគីកម្មករនិយោជិតផ្តល់បង្កាន់ដៃនេះ យ៉ាងយូរត្រឹមថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ប៉ុន្តែភាគីកម្មករនិយោជិតមិនបានដាក់ភស្តុតាងនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ នៅថ្ងៃសវនាការ មានកម្មករនិយោជិតចំនួន ៤ នាក់ នៃក្រុមហ៊ុន ភីសគ្លូរី ដែលបានលើកឡើងថា ពួកគាត់ជាថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ភីសគ្លូរី និងមន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា ០២ នាក់ បានមកចូលរួមសវនាការ។

មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារនេះទទួលស្គាល់ ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនេះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំនិងកិច្ចការរដ្ឋបាល ទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីសុំចុះបញ្ជិកា។...ក្នុងរយៈពេលពីរខែ ក្រោយពីបានទទួលសំណុំបែបបទសុំចុះបញ្ជិកា បើក្រសួងទទួលបន្ទុកវិស័យការងារមិនបានឆ្លើយតប ត្រូវចាត់ទុកអង្គការវិជ្ជាជីវៈនោះថា បានចុះបញ្ជិការួចហើយ..."* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៦៨ ខាងលើនេះ មានន័យថា អង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារទទួលស្គាល់ នៅពេលដែលអង្គការវិជ្ជាជីវៈនោះទទួលបានការចុះបញ្ជិកានៅក្រសួងទទួលបន្ទុកវិស័យការងារ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ឃើញដែរថា សិទ្ធិ និងផលប្រយោជន៍នេះ រួមបញ្ចូលទាំងសិទ្ធិរបស់សហជីពក្នុងការតំណាងសមាជិករបស់ ខ្លួនមកដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៦-ឃ្វីក ស៊ូ ហេតុផលចំណុចវិវាទទី២, លេខ ៣០/០៨-អ៊ី ហ្គាមេន ហេតុផលចំណុចវិវាទទី១, លេខ ៣១/០៨-សៅធន៏ បេរ ហេតុផលចំណុចវិវាទទី១ លេខ ៩៤/០៩-តាកហ្វាត, លេខ ៩២/១៣- អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) និងលេខ ១១០/១៣ ហាយ ហ្វូ)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។

លើសពីនេះ ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬអ្នកតំណាង ដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

យោងតាមប្រការ១៩ នៃប្រកាសលេខ ៩៩/០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា *"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"* មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួនក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាតែបុគ្គលនោះទទួលបានការអនុញ្ញាតជាលាយ

THE ARBITRATION COUNCIL

*លក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៦១/០៩-សិប្បកម្ម ព្រែកព្រៃង, លេខ ៤៣/១០-ម៉ីង ជៀន , លេខ ១៤៤/១២-អ៊ី ហ្គាមេន , លេខ ៩២/១៣- អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) និងលេខ ១១០/១៣ -ហាយ ហ៊្វូ )។*

ដូចនេះ យោងតាមមាត្រា ២៦៨ នៃច្បាប់ស្តីពីការងារ និង ប្រការ ១៩ នៃប្រកាសលេខ ៩៩/០៤ ខាងលើ និងសេចក្តីបង្គាប់មុនៗរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖

- ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការសន្និដ្ឋានពីភាពជាអង្គការវិជ្ជាជីវៈ របស់សហជីពកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ភីសគ្គីរី ដែលគួរទទួលបានសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលច្បាប់ស្តីពីការងារទទួលស្គាល់ទេ ក្នុងខណៈដែលពួកគាត់មិនទាន់ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីព។ ហេតុនេះ កម្មករនិយោជិតទាំង ៤ នាក់ ដែលបានមកចូលរួមសវនាការ មិនមានសិទ្ធិស្របច្បាប់ក្នុង ការតំណាងឱ្យសមាជិករបស់ខ្លួនដែលជាកម្មករនិយោជិតនៃ ក្រុមហ៊ុន ភីសគ្គីរី នៅក្នុងសំណុំរឿង នេះ ទេ។
- មន្ត្រីសហព័ន្ធ ដែលមានវត្តមានពេលសវនាការមិនមានសិទ្ធិស្របច្បាប់ ក្នុងការតំណាងឱ្យកម្មករនិយោជិតដទៃទៀតនៃ ក្រុមហ៊ុន ភីសគ្គីរី ទេ ខណៈដែលមិនមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវពីកម្មករនិយោជិតទាំងនោះ។
- ទោះជាយ៉ាងណាក៏ដោយ កម្មករនិយោជិតចំនួន ៤ នាក់ នៃក្រុមហ៊ុន ភីសគ្គីរី បានចូលរួមផ្ទាល់ក្នុងសវនាការអាជ្ញាកណ្តាល។ កម្មករនិយោជិតទាំង ៤ នាក់ គឺ ១) កម្មករ ចាប សម្បត្តិ, ២) កម្មករ ឡុង នាន, ៣) កម្មករ នែម សុភ័ណ្ឌ និង ៤) កម្មករ អែម ភារម្យ។ ដូចនេះ ផ្អែកតាមប្រការ ១៩ នៃប្រកាសលេខ ៩៩/០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា មានតែកម្មករនិយោជិត ៤ នាក់ ដែលមានរាយនាមខាងលើ គឺជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។

**២) តើការអនុវត្តនៅក្នុងក្រុមហ៊ុន ទាក់ទងនឹងការបើកប្រាក់សម្រាកលំហែមាតុភាពស្មើនឹង ៥០ ភាគរយ នៃប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ជូនកម្មការិនីនៅក្នុងក្រុមហ៊ុន ត្រឹមត្រូវតាមកំណត់ស្តីពីការងារ ដែរ ឬទេ?**

នៅក្នុងអង្គហេតុនៃសំណុំរឿងនេះ និយោជកបានបើកប្រាក់សម្រាកលំហែមាតុភាពស្មើនឹង ៥០ ភាគរយ នៃប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំមួយខែម្តងៗជូនកម្មការិនី ក្នុងអំឡុងពេលសម្រាកលំហែមាតុភាព ឬបីខែម្តងក្រោយពេល ដែលកម្មការិនី ត្រលប់មកពីសម្រាកលំហែមាតុភាព ចូលធ្វើការវិញ។

មាត្រា ១៨២ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ចែងថា ៖ *"ក្នុងសហគ្រាសទាំងអស់ ដែលមានរាប់ក្នុង មាត្រា ១ នៃច្បាប់នេះ ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សម្រាកកៅសិបថ្ងៃ ដើម្បីសម្រាលកូន "* ។

មាត្រា ១៨៣ នៃច្បាប់ស្តីពីការងារដដែលនេះ ចែងថា ៖ *"ក្នុងពេលដែលឈប់សម្រាកដូច មានចែងក្នុងមាត្រាខាងលើនេះ ស្ត្រីមានសិទ្ធិត្រូវបានប្រាក់ឈ្នួលពាក់កណ្តាល គិតទាំងប្រាក់បន្ទាប់បន្សំផង ដោយនិយោជកបើកឱ្យ*

*...*

*ក៏ប៉ុន្តែ ការទទួលប្រាក់ឈ្នួលដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ នឹងឱ្យបានតែចំពោះស្ត្រីណាដែលធ្វើការក្នុងសហគ្រាសបានយ៉ាងតិចមួយឆ្នាំរៀងមក "* ។

យោងតាមមាត្រា ១៨២ និងមាត្រា ១៨៣ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់

ឃើញថា និយោជកមានកាតព្វកិច្ចត្រូវផ្ដល់ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួនពាក់កណ្ដាល ជូនដល់កម្មការិនីដែលត្រូវលំហែមាតុភាពរយៈពេល ៩០ ថ្ងៃ។

មាត្រា១១៥ កថាខ័ណ្ឌទី៣នៃច្បាប់ការងារស្ដីពីការងារដដែល ចែងថា ៖ "*ការបើកប្រាក់ឈ្នួល មិនត្រូវធ្វើនៅថ្ងៃដែល កម្មករនិយោជិតមានសិទ្ធិឈប់សម្រាកឡើយ។ ប្រសិនបើការបើកប្រាក់ចំលើថ្ងៃឈប់នោះ ត្រូវធ្វើមុនមួយថ្ងៃ*"។

មាត្រា ១០៣ នៃច្បាប់ស្ដីពីការងារដដែលនេះ ចែងថា ៖ "*ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ ៖*

*-ប្រាក់ឈ្នួលសុទ្ធសាធ*

*-ប្រាក់ការងារបន្ថែមម៉ោង*

*-ប្រាក់ដែលបើកជាម្ហូប*

*...*

*-ចំនួនប្រាក់ដែលនិយោជកត្រូវផ្ដល់ឱ្យក្នុងពេលបាត់បង់សមត្ថភាពពលកម្ម និងក្នុងពេលលំហែមាតុភាព*"។

ផ្អែកតាមខ្លឹមសារមាត្រា ១១៥ និងមាត្រា ១០៣ នៃច្បាប់ស្ដីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា បទប្បញ្ញត្តិនៃមាត្រា ១១៥ ខាងលើ គឺត្រូវអនុវត្តចំពោះការបើកប្រាក់សម្រាកលំហែមាតុភាពរយៈពេល ៩០ ថ្ងៃ ឱ្យកម្មការិនី ដែលត្រូវសម្រាកលំហែមាតុភាពផងដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មការិនីដែលត្រូវឈប់សម្រាកលំហែមាតុភាព មានសិទ្ធិទទួលប្រាក់លំហែមាតុភាពរយៈពេល៩០ថ្ងៃ មុនពេលពួកគេចាប់ផ្ដើមឈប់សម្រាក។ (*សូមមើលសេចក្ដីបង្គាប់លេខ ១៣៩/០៨-ស៊ុបព្រីម ហ្គាមិន ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី៨ ,លេខ ១០៩/០៩-យូអេសអេ ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី៧, លេខ២២៧/១២-យីងដុង ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី១២, លេខ៣៥/១៣ - នីច-ធី អ៊ីកែវីល ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី៤, លេខ៣៧/១៣- នីច-ធី អ៊ីកែវីល ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី២ និងលេខ ១២/១៤-យូហ្វីថេលើរ ខបភើរេសិន ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី១ .ខ)*។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏ឯកភាពលើការបកស្រាយរបស់អាជ្ញាកណ្ដាលក្នុងសំណុំរឿងមុនៗដែរ គឺនិយោជកត្រូវបើកប្រាក់លំហែមាតុភាពរយៈពេល ៩០ ថ្ងៃ ឱ្យកម្មការិនីដែលត្រូវឈប់សម្រាកលំហែមាតុភាពមុនពេល ដែលពួកគេចាប់ផ្ដើមការឈប់សម្រាកលំហែមាតុភាព។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះយល់ឃើញថា ការអនុវត្តនៅក្នុងក្រុមហ៊ុនដែល និយោជកបានបើកប្រាក់សម្រាកលំហែមាតុភាពចំនួន ៥០ ភាគរយ នៃប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ក្នុងមួយខែម្ដងៗ ជូនកម្មការិនី ក្នុងអំឡុងពេលសម្រាកលំហែមាតុភាព ឬបីខែម្ដងក្រោយពេលដែលកម្មការិនីត្រលប់មកពីសម្រាកលំហែមាតុភាព ចូលធ្វើការវិញ គឺមិនត្រឹមត្រូវតាមច្បាប់ស្ដីពីការងារទេ ដូច្នេះ និយោជកត្រូវបើកប្រាក់លំហែមាតុភាព ចំនួន ៥០ ភាគរយ ជូនកម្មការិនី ដែលឈប់សម្រាកលំហែមាតុភាព រយៈពេល ៩០ ថ្ងៃ មុនពេលឈប់សម្រាកលំហែមាតុភាព។

ប៉ុន្តែ យោងតាមការបកស្រាយត្រង់ " ១" ខាងលើ ប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ដើមបណ្ដឹងក្នុងសំណុំ

រឿងនេះ គឺកម្មករនិយោជិតចំនួន ៤ នាក់ ១)កម្មករ ចាប សម្បត្តិ, ២) កម្មករ ឡុង នាន, ៣) កម្មករ ឆែម សុភ័ណ្ឌ និង ៤) កម្មករ អែម ភារម្យ ដែលសុទ្ធតែជាបុរស។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនៅ ក្នុងចំណុចវិវាទនេះ គឺផ្តល់អត្ថប្រយោជន៍ចំពោះតែកម្មការិនីប៉ុណ្ណោះ។ ពោលគឺ កម្មករនិយោជិត ដែលជាបុរសមិន មានសិទ្ធិទទួលបានប្រាក់លំហែមាតុភាពចំនួន ៥០ ភាគរយនេះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនសម្រេច សេចក្តីលើចំណុចវិវាទនេះ សម្រាប់ដើមបណ្តឹងដែលជាបុរសទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកបើកប្រាក់លំហែមាតុភាពចំនួន ៥០ ភាគរយ សម្រាប់កម្មការិនីឈប់សម្រាកលំហែមាតុភាពចំនួន ៩០ ថ្ងៃ មុនពេលកម្មការិនីឈប់ទៅសម្រាកលំហែមាតុភាព។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ០២ ៖**

បដិសេធការការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកបើកប្រាក់លំហែមាតុភាពចំនួន ៥០ ភាគរយ សម្រាប់កម្មការិនីឈប់សម្រាកលំហែមាតុភាពចំនួន ៩០ថ្ងៃ មុនពេលកម្មការិនីឈប់ទៅសម្រាកលំហែមាតុភាព។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------